ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៥-០៤-២០៥ [illegible]

# ប្រកាស
## ស្តីពី
## សោហ៊ុយអាជ្ញាប័ណ្ណរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

**ទេសាភិបាលធនាគារជាតិនៃកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៤៤ ចុះថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា
- យោងតាមស្មារតីរបស់អង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០៤ ។

## សម្រេច

**ប្រការ ១.-**

កំណត់សោហ៊ុយអាជ្ញាប័ណ្ណសំរាប់ប្រកបមុខរបររបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងការិយាល័យតំណាង តាមប្រការជាបន្តបន្ទាប់ ដូចខាងក្រោម ។

**ប្រការ ២.-**

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងការិយាល័យតំណាង ត្រូវបង់សោហ៊ុយអាជ្ញាប័ណ្ណប្រចាំឆ្នាំ នៅធនាគារជាតិ នៃកម្ពុជា ដូចខាងក្រោម ៖

ក- ធនាគារពាណិជ្ជ ៖

| | | |
|---|---|---|
| ១- | ទីស្នាក់ការកណ្តាល | : ៧០.០០០.០០០ រៀល |
| ២- | សាខាខេត្ត-ក្រុងទី ៧ ចុះ | : ៥៦.០០០.០០០ រៀល ក្នុងមួយសាខា |
| ៣- | សាខាទី ៨ ឡើង | : ២០.០០០.០០០ រៀល ក្នុងមួយសាខា |
| ៤- | សាខាស្រុក | : ១.០០០.០០០ រៀល ក្នុងមួយសាខា |

ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ខ- ធនាគារឯកទេស ៖

១- ទីស្នាក់ការកណ្ដាល : ១០.០០០.០០០ រៀល

២- សាខាទី ៧ ចុះ : ៨.០០០.០០០ រៀល ក្នុងមួយសាខា

៣- សាខាទី ៨ ឡើង : ៥.០០០.០០០ រៀល ក្នុងមួយសាខា

គ- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ : ១.០០០.០០០ រៀល

ឃ-ការិយាល័យតំណាងធនាគារបរទេស: ៧០.០០០.០០០ រៀល ។

**ប្រការ ៣.-**

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងការិយាល័យតំណាង ដែលបើកទីស្នាក់ការកណ្ដាល ឬ សាខានៅក្នុងឆ្នាំ ត្រូវបង់សោហ៊ុយអាជ្ញាប័ណ្ណ ដូចខាងក្រោម ៖

- ក្នុងត្រីមាសទីមួយ : ត្រូវបង់ពេញមួយឆ្នាំ
- ក្នុងត្រីមាសទីពីរ : ត្រូវបង់បីត្រីមាស
- ក្នុងត្រីមាសទីបី : ត្រូវបង់ពីរត្រីមាស
- ក្នុងត្រីមាសទីបួន : ត្រូវបង់មួយត្រីមាស ។

**ប្រការ ៤.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាពគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទនិងក្រោមអាណាព្យាបាល ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៥.-**

ប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៦.-**

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០០៤

ទេសាភិបាល

ជា_ចាន់តូ

**<u>កន្លែងទទួល</u>**

- ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ និង ឯកសារ

**<u>ចម្លងជូន</u>**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្ដីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាពត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្ដីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះក្នុងរាជកិច្ច"